ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៣២៩

ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២

**សាលដីកា**

លេខ ៣៦១ "VI"

ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣

ដោយអង្គជំនុំជម្រះដែលមានសមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-ឯកឧត្តម [redacted] ជាចៅក្រម

៣-ឯកឧត្តម [redacted] ជាចៅក្រម

៤-លោកជំទាវ [redacted] ជាចៅក្រម

៥-ឯកឧត្តម [redacted] ជាចៅក្រម

**ចៅក្រមរបាយការណ៍**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] បាន:ជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៩៥ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ម៉ាអ៊ែន ក្នុងការប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ២៤ ក្រ IV "សស" ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

**-បុគ្គលប្តឹងសាទុក្ខជនជាប់ចោទឈ្មោះ** [redacted] **ម៉ាអ៊ែន** ភេទប្រុស អាយុ ៥០ឆ្នាំ ជនជាតិខ្មែរ មុខរបរនគរបាល ទីកន្លែងកំណើតនៅភូមិ [redacted] ក្រុងភ្នំពេញ លំនៅមុនពេលឃុំខ្លួននៅ [redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ ហេង ប៊ុនថៃ (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] គ្មានកូន ទោសពីមុនគ្មាន។

-ដីកាបង្គាប់ឱ្យឃុំខ្លួន ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤។

**ជាប់ចោទពីបទឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ។

-មានលោក [redacted] **ម៉ូរា** និងលោក [redacted] **ចិ៊ុនធា** ជាមេធាវីការពារសិទ្ធិ។

**-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] **វល័ក្ខណ៍** ភេទស្រី អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកធនាគារអេស៊ីលីដា ទីកន្លែងកំណើត [redacted] ខេត្តកំពង់ចាម លំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] “ស” ម្តាយឈ្មោះ [redacted] “ស” ប្តីឈ្មោះ [redacted] មានកូនចំនួន ០១ នាក់។

-មានលោក [redacted] **ស្មើសេរីវង្ស** ជាមេធាវីការពារសិទ្ធិ។

**អំពីអង្គហេតុ៖**

កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៤ វេលាម៉ោងប្រហែល២៣ និង៣០ នៅចំណុចផ្ទះជួលស្ថិតនៅភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម មានឈ្មោះ [redacted] ម៉ារ៉ែន ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ បានធ្វើសកម្មភាពប្លន់យកទ្រព្យសម្បត្តិ ហើយយកប្រេងសាំងចាក់ដុតទៅលើជនរងគ្រោះឈ្មោះ [redacted] សាថាត ភេទប្រុស អាយុ ៥៤ឆ្នាំ បណ្តាលឱ្យស្លាប់បន្ទាប់ពីបញ្ជូនទៅមន្ទីរពេទ្យ។ បន្ទាប់ពីហេតុការណ៍នេះកើតឡើងកម្លាំងសមត្ថកិច្ចបានរៀបចំកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តកំពង់ចាមចាត់ការតាមនីតិវិធី។

**-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣៣ “ក” ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖**

១-ផ្តន្ទាទោសឈ្មោះ [redacted] ម៉ារ៉ែន ភេទប្រុស អាយុ ៤៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៣០ “សាមសិប” ឆ្នាំ ពីបទឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៤ តាមមាត្រា២០០ និងមាត្រា ៩៣ , ៩៥ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ែន សងសំណងការអន្តរាយនិងជំងឺចិត្តជាទឹកប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វល័ក្ខណ៍ ។ ការទាមទារលើសនេះលើកចោល។

៣-វត្ថុតាងរួមមាន៖ ទូរស័ព្ទដៃអិនចុចពិលចំនួន ២ គ្រឿង (ពណ៌ក្រហមនិងពណ៌ខ្មៅ) ប្រាក់ដុល្លារចំនួន ៣៥០ (បីរយហាសិប) ដុល្លារអាមេរិក ត្រូវរឹបអូសតាមមាត្រា៦២ និងមាត្រា៦២ និង៦៣ នៃក្រមព្រហ្មទណ្ឌ។

៤-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ែន និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វល័ក្ខណ៍ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គឹមស្រ៊ី ទុកជាសិទ្ធប្តឹងទាស់និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-**បានឃើញ** បណ្តឹងឧទ្ធរណ៍តាមពាក្យបណ្តឹងលេខ៣១៤ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted]ម៉ាអ៊ែន បានប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៣ "ក" ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តកំពង់ចាម ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ២៤ ក្រIV "សស" ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖**

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣១៤ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted]ម៉ាអ៊ែន ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ខ្លះ។

២-កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted]ម៉ាអ៊ែន (សាវតារជាតិដូចខាងលើ) ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៤ តាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ មកជាបទ ឃាតកម្ម តាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

៣-តម្កល់សាសក្រមព្រហ្មទណ្ឌលេខ ៣៣ "ក" ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តកំពង់ចាម ទុកជាបានការ លើកលែងត្រង់សេចក្តីសម្រេចផ្តន្ទាទោសលើឈ្មោះ ហេង ម៉ាអ៊ែន (សាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ៣០ (សាមសិប)ឆ្នាំ ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៤ តាមមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ ត្រូវកែប្រែមកផ្តន្ទាទោសលើឈ្មោះ[redacted] ម៉ាអ៊ែន ដាក់ពន្ធនាគារកំណត់ ១៥ (ដប់ប្រាំ) ឆ្នាំ ពីបទឃាតកម្ម តាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌវិញ និងបដិសេធចោលសេចក្តីសម្រេចត្រង់ចំណុចទី៣ នៃសាលក្រមនេះ ដោយសម្រេចប្រគល់វត្ថុតាងចាប់យកមានទូរស័ព្ទដៃអិនចុចពិលចំនួន ២ គ្រឿង និងប្រាក់ចំនួន ៣៥០$ ឱ្យជនជាប់ចោទម្ចាស់ដើមឈ្មោះ [redacted] ម៉ាអ៊ែន វិញ។ ចំណុចផ្សេងពីនេះរក្សាទុកដដែល។

សាលដីកានេះជំនុំជម្រះជាសាធារណៈនាសាលសវនាការសាលាឧទ្ធរណ៍ភ្នំពេញនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]ម៉ាអ៊ែន កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]គីមស្រ៊ី និងឈ្មោះ[redacted]វល័ក្ខណ៍ ។

ទុកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-**បានឃើញ** បណ្តឹងសាទុក្ខលេខ ៩៥ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ម៉ាអ៊ែន បានប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ២៤ ក្រIV "សស" ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០២២ របស់សភាសាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល។

-**បានឃើញ** សារណាការពារ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ[redacted]ម៉ាអ៊ែន។

-**បានឃើញ** សារណាតប ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]វល័ក្ខណ៍។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍ឡើងធ្វើសេចក្តីរាយការណ៍ ។

-សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលបានលើកឡើងថា តាមការពិនិត្យលើកភស្តុតាងដែលតុលាការអង្គហេតុលើយកមកនេះ ភស្តុងតាងទាំងនេះគឺជាភស្តុតាងប្រយោលនិងមែនជាភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទបានប្រព្រឹត្តឡើយ។ ហេតុដូច្នេះតំណាងមហាអយ្យការប្ដឹងសុំចំពោះតុលាការកំពូលសុំឱ្យពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់។

-លោក [redacted] បូរ៉ា ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ែន បានធ្វើសេចក្ដីសន្និដ្ឋានថា ការសម្រេចផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ែន ដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ ពីបទឃាតកម្ម ប្រព្រឹត្តនៅភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៤ តាមមាត្រា ១៩៩ និងមាត្រា៩៣ ,មាត្រា៩៥ នៃក្រមព្រហ្មទណ្ឌ ដោយពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទេ ហើយភស្តុតាងដែលតុលាការអង្គហេតុលើកមកសំអាងដាក់បន្ទុកសុទ្ធតែជាភស្តុតាងប្រយោល។ ជនជាប់ចោទទៅជួបសួរសុខទុក្ខម្ដាយពុំមែនជាការរត់គេចខ្លួនឡើយ កូនក្ដីខ្លួនប្ដឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ២២៤ ក្រIV "សស" ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍គ្រង់សម្រេចទាំងមូល។ ក្នុងរឿងក្ដីនេះមានវិមតិសង្ស័យដូច្នេះត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ផ្អែកតាមបញ្ញត្តិមាត្រា៣៨ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា និងមាត្រា ៣៥១ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

<u>សំណូមពរ</u> សូមក្រុមប្រឹក្សាមេត្តាសម្រេចបដិសេធសាលដីកាសាលាឧទ្ធរណ៍ចោលជាអសារបង់។

-ជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ែន បានឆ្លើយថា ខ្លួនសូមឯកភាពតាមសេចក្ដីសន្និដ្ឋានរបស់លោកមេធាវីការពារសិទ្ធិទាំងស្រុង។

-លោក [redacted] រស្មីសេរីវង្ស ជាមេធាវីការពារឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] វល័ក្ខណ៍ បានធ្វើសេចក្ដីសន្និដ្ឋានថា ជនជាប់ចោទត្រូវបានតុលាការចោទប្រកាន់ពីបទឃាតកម្មគិតទុកជាមុន តាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ហើយតុលាការខេត្តកំពង់ចាមបានសម្រេចផ្ដន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារកំណត់រយៈពេល ៣០ឆ្នាំ ជនជាប់ចោទបានប្ដឹងឧទ្ធរណ៍ ហើយសាលាឧទ្ធរណ៍បានកែប្រែបទចោទពីបទឃាតកម្មគិតទុកជាមុន ទៅជាបទចោទឃាតកម្ម ហើយត្រូវដាក់ពន្ធនាគារកំណត់រយៈពេល ១៥ឆ្នាំ។ ពាក់ព័ន្ធតាមអង្គហេតុកាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៤ វេលាម៉ោងប្រហែល២៣ និង៣០ នាទីយប់ នៅចំណុចផ្ទះជួលស្ថិតនៅភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម មានករណីជុតសម្លាប់ឪពុករបស់កូនក្ដីខ្លួន ហើយជនជាប់ចោទនិងឪពុករបស់កូនក្ដីខ្លួនជាអ្នកស្គាល់និងរាប់អានគ្នា។ នៅថ្ងៃកើតហេតុ ម្ចាស់ផ្ទះបានឃើញជនជាប់ចោទរត់ចេញពីបន្ទប់របស់ជនរងគ្រោះ ប៉ុន្តែជនជាប់ចោទបានឆ្លើយបដិសេធគ្រប់នីតិវិធីទាំងអស់ តែសកម្មភាពរបស់ជនជាប់ចោទមានភាពស៊ីសង្វាក់គ្នាទៅនឹងភស្តុតាងហើយ។

<u>សំណូមពរ</u> សូមក្រុមប្រឹក្សាមេត្តាសម្រេចតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការដដែល។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] វល័ក្ខណ៍ បានធ្វើសេចក្ដីសន្និដ្ឋានថា ខ្លួនសូមឯកភាពតាមសេចក្ដីសន្និដ្ឋានរបស់លោកមេធាវីការពារសិទ្ធិទាំងស្រុង។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនិងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី

- ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

**តុលាការកំពូល**

**១-យល់ឃើញថា** បណ្តឹងសាទុក្ខលេខ ៩៥ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ែន** ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមបញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤១៧ , មាត្រា ៤១៨ , មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**២-យល់ឃើញថា** នាពេលពិភាក្សាដេញដោល មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានលើកឡើងអំពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទថា ជាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ម៉ារ៉ែន** ដាក់ពន្ធនាគារកំណត់ ១៥ (ដប់ប្រាំ) ឆ្នាំ ពីបទឃាតកម្ម ប្រព្រឹត្តនៅភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៤ តាមមាត្រា ១៩៩ និងមាត្រា ៩៣ , មាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ ដោយពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទេ ហើយភស្តុតាងដែលតុលាការអង្គហេតុលើកមកសំអាងដាក់បន្ទុកសុទ្ធតែជាភស្តុតាងប្រយោល។ ជនជាប់ចោទទៅជួបសួរសុខទុក្ខម្តាយពុំមែនជាការរត់គេចខ្លួនឡើយ កូនក្តីខ្លួនប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ២៤ ក្រIV “សស” ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញគ្រង់សម្រេចទាំងមូល។ ក្នុងរឿងក្តីនេះមានវិមតិសង្ស័យ ដូច្នេះត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ផ្អែកតាមបញ្ញត្តិមាត្រា ៣៨ រដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា និងមាត្រា ៣៥១ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នោះតុលាការកំពូលពិចារណាឃើញថា ជាសេចក្តីសន្និដ្ឋានមានមូលហេតុសំអាងសមស្របតាមបញ្ញត្តិមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ម៉្យាងទៀត ប្រសិនបើសាលាឧទ្ធរណ៍មានជំនឿជាក់ទៅលើបណ្តាភស្តុតាងប្រយោលទាំងនេះ សាលាឧទ្ធរណ៍ក៏គប្បីពិចារណាសម្រេចនិងប្រកាសទោសចំពោះជនជាប់ចោទក្នុងកម្រិតមួយសមស្របដែរ មិនគួរគប្បីសម្រេចនិងប្រកាសទោសក្នុងកម្រិតអតិបរមាដោយគ្មានសំអាងហេតុសមស្របដូច្នេះឡើយ។

**៣-យល់ឃើញថា** សារណាបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទបានលើកឡើងថា ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ភ្នំពេញដែលតម្កល់សាលក្រមលេខ៣៣ “ក” ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តកំពង់ចាមដដែល ដោយគ្រាន់តែកែប្រែបទចោទពីបទឃាតកម្មគិតទុកជាមុន(តាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ)មកជាបទឃាតកម្ម (តាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ)វិញ ពីជាប់ទោស ៣០ ឆ្នាំ មកជាប់ទោស ១៥ ឆ្នាំវិញ គឺមានភាពអយុត្តិធម៌ចំពោះខ្លួនខ្លាំងណាស់ ពីព្រោះខ្លួនមិនបាន

ប្រព្រឹត្តដូច ការចោទប្រកាន់នោះទេ ហើយខ្លួនក៏បានឆ្លើយបំភ្លឺរាល់ដំណាក់កាលតាំងពីការស៊ើបសួររហូត សវនាការកន្លងមក ។ មិនតែប៉ុណ្ណោះរាល់ការបំភ្លឺនៅចំពោះមុខតុលាការសាលាដំបូងខេត្តកំពង់ចាមរបស់សាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវជាកូនរបស់ជនរងគ្រោះដែលបាន ជួយជនរងគ្រោះផ្ទាល់ទាំងក្នុងពេលកើតហេតុនិងរហូតដល់បញ្ជូនទៅមន្ទីរពេទ្យលោកសង្ឃ និងមុនពេលពេទ្យចាក់ថ្នាំសង្គ្រោះ ហើយបានស្លាប់នៅពេលទាបភ្លឺនោះ ក៏ពុំបានឆ្លើយបញ្ជាក់មានជាប់ពាក់ព័ន្ធនឹងឈ្មោះខ្លួនថាបានប្រព្រឹត្តដែរ ។ ដូច្នេះការសម្រេចសេចក្តីរបស់សាលាដំបូងខេត្តកំពង់ចាមនិងសាលាឧទ្ធរណ៍ភ្នំពេញពុំបានផ្តល់យុត្តិធម៌ដល់រូបខ្លួនឡើយ ។ ម៉្យាងទៀតខ្លួនបានជាប់ឃុំនៅមណ្ឌលអប់រំកែប្រែទី៣ (ម.៣) ពាំងថ្លុង អស់រយៈពេល ៨ ឆ្នាំ មកហើយ ខ្លួនមានជំងឺប្រចាំកាយ ទើបដាក់ពាក្យប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ២៤ ក្រIV "សស" ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីសុំឱ្យតុលាការកំពូលផ្តល់ភាពស្អាតស្អំឱ្យខ្លួន នោះតុលាការកំពូលពិចារណាឃើញថា គឺជាអំណះអំណាងមាន លក្ខណៈសមស្រប ។

**៤-យល់ឃើញថា** សេចក្តីសន្និដ្ឋានលាយលក្ខណ៍អក្សរ ក៏ដូចជាសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់នាពេលសវនាការរបស់តំណាងមហាអយ្យការអមតុលាការកំពូលបានលើកឡើងថាភស្តុតាងដែលតុលាការអង្គហេតុលើកមកនេះជាភស្តុតាងប្រយោល មិនមែនជាភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់បញ្ជាក់ថាជនជាប់ចោទបានប្រព្រឹត្តអំពើឃាតកម្មនោះទេ នោះតុលាការកំពូល ពិចារណាឃើញថា គឺជាសេចក្តីសន្និដ្ឋានមានមូលដ្ឋានសំអាងលើភស្តុតាងភស្តុតាងនិងអង្គច្បាប់សមស្រប ហើយក៏សមស្របទៅនឹងផ្នែកសំអាងហេតុ ត្រង់ចំណុចផ្សេងទៀតរបស់តុលាការកំពូលដែរ ។

**៥-យល់ឃើញថា** សេចក្តីសន្និដ្ឋានលាយលក្ខណ៍អក្សរ ក៏ដូចជាសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់នាពេលសវនាការរបស់មេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងអះអាងថាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ នោះគឺជាសេចក្តីសន្និដ្ឋានពុំមានមូលដ្ឋានសំអាងលើភស្តុតាងណាមួយបានជាក់ច្បាស់នោះទេ ។

**៦-យល់ឃើញថា** សាលដីកាព្រហ្មទណ្ឌលេខ ២៤ ក្រIV "សស" ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញដែលបានសម្រេចសេចក្តីមកនេះមិនត្រឹមត្រូវតាមគតិច្បាប់ទេ ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

**១-ទទួល** បណ្តឹងសាទុក្ខលេខ ៩៥ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ែន។

**២-បដិសេធ** សាលដីកាព្រហ្មទណ្ឌលេខ ២៤ ក្រIV "សស" ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ។

**៣-បញ្ជូន** សំណុំរឿងព្រហ្មទណ្ឌលេខ ៣២៩ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ភ្នំពេញដើម្បីជំនុំជម្រះសាជាថ្មីឡើងវិញ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ ។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ជាប្រធាន |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកជំទាវ | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកស្រី | [redacted] | ជាក្រឡាបញ្ជី |

---

**បានចម្លងត្រឹមត្រូវតាមសាលដីកាដើម។**

ថ្ងៃសុក្រ ០៦កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃសុក្រ ០៦កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣

**ប្រធានអង្គជំនុំជម្រះ**

[redacted]